ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ៣៣៤៨ ព.ណ..កផ...

ថ្ងៃ សុក្រ ១៣កើត ខែ កត្តិក ឆ្នាំជូតទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០២០

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទូទៅ បងប្អូនផលិតករ អាជីវករ សហគ្រាសធុនតូច និងមធ្យមកម្ពុជា ដែលបានដាក់ពាក្យចូលរួមតាំងបង្ហាញផលិតផលខ្មែរ ក្នុងឱកាសនៃការរៀបចំយុទ្ធនាការទិញផលិតផលខ្មែរជុំវិកាលទី៥ ឆ្នាំ២០២០ នៅខេត្តសៀមរាបចាប់ពីថ្ងៃទី២១-២៤ ខែវិច្ឆិកា ឆ្នាំ២០២០ និងនៅខេត្តព្រះវិហារ ចាប់ពីថ្ងៃទី២៣-២៦ ខែវិច្ឆិកា ឆ្នាំ២០២០ ឲ្យបានជ្រាបថា៖ អនុវត្តតាម គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចូលរួមទប់ស្កាត់នូវការរីករាលដាលនៃជំងឺឆ្លងកូវីដ-១៩ ឲ្យបាន ទាន់ពេលវេលា ក្រសួងពាណិជ្ជកម្ម សូមប្រកាសលើកពេលរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ក្នុងខេត្តទាំងពីរខាង លើរហូតដល់មានសេចក្តីជូនដំណឹងជាថ្មី។

ចំពោះព័ត៌មានលម្អិត សូមទាក់ទងនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ដែលមាន ទីតាំងស្ថិតនៅជាន់ទីពីរនៃអគារ ទីស្តីការក្រសួងពាណិជ្ជកម្ម អាសយដ្ឋាន៖ ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ទូរស័ព្ទទាក់ទង៖ ០៧៧ ៣៣ ២២ ៣៣ ឬ ០៧៧ ៣៣៩ ៤៣៩
អាសយដ្ឋានអ៊ីម៉ែល៖ neary86@yahoo.com

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម